**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ ..........៥៧៨.......... គ.ប/ប្រ.ក.អ.ធ.ក

# ប្រកាស
# ស្តីពី
# ការឈប់បុណ្យដែលមានប្រាក់ឈ្នួល ប្រចាំឆ្នាំ២០១៩

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញមាត្រា១៦២ នៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៥/៣៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ទៅជាគណៈកម្មការរៀបចំបុណ្យជាតិ-អន្តរជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២៨៣អនក្រ/បក. ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ/ប.ក ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៨ របស់រាជរដ្ឋាភិបាលស្តីពីទិវាជាតិនៃការចងចាំ
- បានឃើញអនុក្រឹត្យលេខ ១២៦ អនក្រ.បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៨ ស្តីពីប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ២០១៩។

## សម្រេច

**ប្រការ១ ._**

ត្រូវបានអនុញ្ញាតឱ្យកម្មករនិយោជិត នៃសហគ្រាស គ្រឹះស្ថាន ទាំងអស់ ដែលមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ បានឈប់សម្រាកការងារដោយមានប្រាក់ឈ្នួល តាមប្រតិទិនដូចខាងក្រោម៖

| | | | |
|---|---|---|---|
| - ថ្ងៃទី ០១ | មករា | ទិវាចូលឆ្នាំសកល | សម្រាក ០១ថ្ងៃ |
| - ថ្ងៃទី ០៧ | មករា | ទិវាជ័យជម្នះលើរបបប្រល័យពូជសាសន៍ | សម្រាក ០១ថ្ងៃ |
| - ថ្ងៃទី ១៩ | កុម្ភៈ | ពិធីបុណ្យមាឃបូជា | សម្រាក ០១ថ្ងៃ |
| - ថ្ងៃទី ០៨ | មីនា | ទិវានារីអន្តរជាតិ | សម្រាក ០១ថ្ងៃ |
| - ថ្ងៃទី ១៤-១៥-១៦ | មេសា | ពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ឆ្នាំកុរ ឯកស័ក | សម្រាក ០៣ថ្ងៃ |
| - ថ្ងៃទី ០១ | ឧសភា | ទិវាពលកម្មអន្តរជាតិ | សម្រាក ០១ថ្ងៃ |



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ:(០២៣)៨៨ ២៧ ៦៥

| | | | |
|---|---|---|---|
| - ថ្ងៃទី ១៣-១៤-១៥ | ឧសភា | ព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម **ព្រះករុណា ព្រះបាទសម្ដេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា | សម្រាក ០៣ថ្ងៃ |
| - ថ្ងៃទី ១៨ | ឧសភា | ពិធីបុណ្យវិសាខបូជា | សម្រាក ០១ថ្ងៃ |
| - ថ្ងៃទី ២០ | ឧសភា | ទិវាជាតិនៃការចងចាំ | សម្រាក ០១ថ្ងៃ |
| - ថ្ងៃទី ២២ | ឧសភា | ព្រះរាជពិធីច្រត់ព្រះនង្គ័ល | សម្រាក ០១ថ្ងៃ |
| - ថ្ងៃទី ០១ | មិថុនា | ទិវាកុមារអន្តរជាតិ | សម្រាក ០១ថ្ងៃ |
| - ថ្ងៃទី ១៨ | មិថុនា | ព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម **សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** | សម្រាក ០១ថ្ងៃ |
| - ថ្ងៃទី ២៤ | កញ្ញា | ទិវាប្រកាសរដ្ឋធម្មនុញ្ញ | សម្រាក ០១ថ្ងៃ |
| - ថ្ងៃទី២៧-២៨-២៩ | កញ្ញា | ពិធីបុណ្យភ្ជុំបិណ្ឌ | សម្រាក ០៣ថ្ងៃ |
| - ថ្ងៃទី ១៥ | តុលា | ទិវាប្រារព្ធពិធីគោរពព្រះវិញ្ញាណក្ខន្ធ **ព្រះករុណាព្រះបាទ សម្ដេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និង ឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ"** | សម្រាក ០១ថ្ងៃ |
| - ថ្ងៃទី ២៣ | តុលា | ទិវារំលឹកខួបនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស | សម្រាក ០១ថ្ងៃ |
| - ថ្ងៃទី ២៩ | តុលា | ព្រះរាជពិធីគ្រងព្រះបរមរាជសម្បត្តិរបស់ **ព្រះករុណា ព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា | សម្រាក ០១ថ្ងៃ |
| - ថ្ងៃទី ០៩ | វិច្ឆិកា | ពិធីបុណ្យឯករាជ្យជាតិ | សម្រាក ០១ថ្ងៃ |
| - ថ្ងៃទី១០-១១-១២ | វិច្ឆិកា | ព្រះរាជពិធីបុណ្យអុំទូក បណ្ដែតប្រទីប និងសំពះព្រះខែ អកអំបុក | សម្រាក ០៣ថ្ងៃ |
| - ថ្ងៃទី ១០ | ធ្នូ | ទិវាសិទ្ធិមនុស្សអន្តរជាតិ | សម្រាក ០១ថ្ងៃ |

**ប្រការ២ .-**

ចំពោះថ្ងៃឈប់សម្រាកបុណ្យទាំងឡាយណា ដែលត្រូវបានឈប់សម្រាកត្រូវចំលើថ្ងៃអាទិត្យនោះ កម្មករនិយោជិតនឹងត្រូវបានឈប់សម្រាកមួយថ្ងៃបន្ថែមទៀត។

**ប្រការ៣ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ មានភារកិច្ចអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ តទៅ។

ថ្ងៃ អង្គារ ១១កើត ខែ មិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល៖**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- គ្រប់មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ រាជធានី-ខេត្ត
- គ្រប់សមាគមនិយោជក
- គ្រប់សហព័ន្ធសហជីព
- ដូចប្រការ ៤
  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- ឯកសារ-កាលប្បវត្តិ